# មេរៀនទី៤៖ ព្រះយេស៊ូវជាព្រះអង្គសង្គ្រោះរបស់យើង

## ម៉ាថាយ ២៖១-១២

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/JS02dYKPbKg

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/1MO892n3ctY

**គោលបំណង៖** ព្រះចង់ឲ្យយើងមានជំនឿថាព្រះយេស៊ូវទ្រង់យាងមកដើម្បីសង្គ្រោះយើង។

**ខគម្ពីរចងចាំ៖ យ៉ូហាន ៣៖១៦** *"ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ។ "*

**ចំរៀង** ( *យូធូបលីង* )៖

១. ណូអែលឆ្នាំនេះ https://youtu.be/A59-uQCZfxE

២. Merry Christmas https://youtu.be/4B-8B5XN-2A

៣. ជូនពរគ្រីស្ទម៉ាស https://youtu.be/krpABa89_RU

៤. ចូរទៅប្រាប់គេនៅឯភ្នំ https://youtu.be/z9qbWLyIWvA

### ១. អធិស្ឋាន

ឱព្រះយេស៊ូវអើយកូនសូមអរគុណទ្រង់ សំរាប់ការជួបជុំគ្នានៅថ្ងៃនេះ សូមយាងព្រះអង្គគង់នៅជាមួយកូន និងបង្រៀនកូនបន្ថែមទៀតអំពីទ្រង់។ កូនសូមអធិស្ថានក្នុងនាមព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត « និយាយថា "ទេ" »

សំភារៈដែលត្រូវការ៖ ស្ករគ្រាប់ ឬអាហារសម្រន់ជានំកញ្ចប់ៗសំរាប់កុមារគ្រប់គ្នា

សូមពន្យល់កុមារថាគ្រូនឹងសួរសំនួរទៅកាន់ពួកគេ ហើយពួកគេអាចឆ្លើយបានតែចម្លើយ "ទេ" ដោយមិនអាចឆ្លើយ ថា " បាទ ឬចាស " បានទេ។

ក. តើប្អូនចូលចិត្តឈ្លោះគ្នាដែរឬទេ ? "ទេ"

ខ. តើប្អូនចូលចិត្តលួចគេដែរឬទេ ? "ទេ"

គ. តើប្អូនចូលចិត្តខឹងដែរឬទេ ? "ទេ"

ឃ. តើប្អូនចូលចិត្តញ៉ាំដែរឬទេ ? "ទេ"

ង. តើប្អូនចូលចិត្តគេងដែរឬទេ ? "ទេ"

ច. តើប្អូនចូលចិត្តស្ករគ្រាប់ដែលគេឲ្យដោយឥតគិតថ្លៃដែរឬទេ ? "ទេ"

ពេលដែលកុមារនិយាយថា "ទេ" ចំពោះស្ករគ្រាប់ ឬអាហារសំរ៉ន់ សូមសួរពួកគេថា តើពួកគេអាចនិយាយថា "ទេ" យ៉ាងដូចម្តេចបានទៅកាន់របស់ល្អទាំងអស់នេះ។ តើពួកគេមានអារម្មណ៍បែបណា នៅពេលដែលនិយាយថា "ទេ" ចំពោះអ្វីដែលជាអំណោយដោយឥតគិតថ្លៃសំរាប់ពួកគេ? ព្រះយេស៊ូវ គឺជាអំណោយសំរាប់យើងរាល់គ្នា តែមានមនុស្សជាច្រើនបាននិយាយថា "ទេ" ចំពោះទ្រង់។ សូមពន្យល់ទៅកុមារថា យើងត្រូវការជួយមនុស្សទាំងអស់នោះ ឲ្យនិយាយថា "បាទ ឬចាស"។ សូមប្រាប់ពួកគេថា ពួកគេអាច

និយាយថា "បាទ ឬចាស" ចំពោះអំណោយ ដែលឥតគិតថ្លៃនេះបាន ហើយសូមសួរទៅពួកគេម្តងទៀតថា តើអ្នកចូលចិត្តស្ករគ្រាប់ ឬអាហារសំរ៉ន់ដែលជាអំណោយឥតគិតថ្លៃដែរឬទេ? ពេលដែលកុមារឆ្លើយ ថា "បាទ ឬចាស" សូមឲ្យស្ករគ្រាប់ឬអាហារសំរ៉ន់ទៅពួកគេ។

## ៤. ការណែនាំមេរៀន

ការប្រសូតរបស់ព្រះយេស៊ូវគឺជាអ្វីដែលយើងត្រូវអបអរសាទរ ពីព្រោះទ្រង់គឺជាចម្លើយចំពោះការសន្យារបស់ព្រះ។ មានមនុស្សរាប់រយ រាប់ពាន់នាក់គ្រប់ជំនាន់តាំងពីសម័យអ័ដាម និងអេវ៉ាមកម្លេះ បានរង់ចាំព្រះយេស៊ូវដែល ត្រូវយាងមក ដើម្បីឲ្យទ្រង់បង្ហាញផ្លូវដល់ពួកគេបានត្រឡប់ទៅរកព្រះវិញ។ ព្រះបានរក្សាការសន្យារបស់ទ្រង់ ដោយទ្រង់បានបញ្ជូនព្រះយេស៊ូវមកលើផែនដី។ នេះជាមូលហេតុនៃការដែលយើងត្រូវអបអរសាទរ! ប៉ុន្តែមានមនុស្សមួយចំនួន ក៏មិនសប្បាយចិត្តជាមួយនឹងកំណើតរបស់ព្រះយេស៊ូវដែរ។ តោះចូរស្វែងយល់ថា តើនរណាខ្លះដែលមិនសប្បាយចិត្ត!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ស្តេចហេរ៉ូឌគឺជាស្តេចរបស់ជនជាតិអ៊ីស្រាអែល នៅពេលដែលព្រះយេស៊ូវប្រសូត ។ ទ្រង់បានក្លាយជាស្តេចជនជាតិអ៊ីស្រាអែលមែន ប៉ុន្តែទ្រង់មិនមែនជាជនជាតិអ៊ីស្រាអែលទេ។ ថ្ងៃមួយហោរ៉ាទាំង៣បានធ្វើដំណើរពីឆ្ងាយមកទឹកដីអ៊ីស្រាអែល ហើយបានចូលគាល់ស្តេចហេរ៉ូឌ។ ពួកគេបានសួរថា **ម៉ាថាយ ២:២** "តើព្រះអង្គដែលប្រសូតមក ធ្វើជាស្តេចសាសន៍យូដាទ្រង់គង់នៅឯណា ពីព្រោះយើងបានឃើញផ្កាយរបស់ទ្រង់ពីទិសខាងកើតមក ហើយយើងមកថ្វាយបង្គំទ្រង់" ។ ព្រះគម្ពីរបានប្រាប់ថា ស្តេចហេរ៉ូឌមានអារម្មណ៍ "វិតក្ក(សញ្ជឹងគិត)ព្រួយ" នៅពេលដែលបានឮរឿងនេះ។ **ម៉ាថាយ ២:៨** "រួចទ្រង់ចាត់ គេឲ្យទៅឯបេថ្លេហិម ដោយបង្គាប់ថា ចូរអ្នករាល់គ្នាទៅស៊ើបដំណឹងពីកូនតូចនោះឲ្យច្បាស់លាស់ កាល- ណាបានឃើញហើយ នោះត្រូវមកប្រាប់ដល់យើងវិញ ដើម្បីឲ្យយើងបានទៅថ្វាយបង្គំដែរ" ។ តាមពិត ស្តេច ហេរ៉ូឌ មិនចង់ថ្វាយបង្គំព្រះ យេស៊ូវទេ! តែគាត់ចង់សម្លាប់ព្រះអង្គសង្គ្រោះវិញ!

ព្រះចេស្តា ការអស្ចារ្យ និងអំណាចដ៏អាថ៌កំបាំងរបស់ព្រះត្រូវបានបើកសម្តែងតាមរយៈកំណើត របស់ព្រះយេស៊ូវ ជាព្រះដែលយាងមកផែនដី គឺជាព្រះពេញលក្ខណៈ និងជាមនុស្សពេញលក្ខណៈ ដូចជាទារកទើបនឹងកើតមកដែលគ្មានទីពឹង។ ព្រះយេស៊ូវនឹងនាំយកមកនូវសេចក្តីសង្គ្រោះ សេចក្តីសង្ឃឹម និងពន្លឺដែលពិភពលោកនេះត្រូវការ ។ មនុស្សមួយចំនួនបានយល់ពីសេចក្តីត្រូវការរបស់ពួកគេ ដោយបានបើកចំហរចិត្តដើម្បីទទួលព្រះយេស៊ូវ ខណៈពេលដែលមនុស្សមួយចំនួនទៀត កំពុងបន្តរស់នៅក្នុងភាព-ងងឹត។ ស្តេចហេរ៉ូឌ គឺជាម្នាក់ក្នុងចំណោមមនុស្សជាច្រើនទៀត ដែលកំពុងរស់នៅក្នុងភាពងងឹត។ ស្តេចហេរ៉ូឌ មិនបានដឹងថា មានតែសេចក្តីជំនឿជាមួយព្រះយេស៊ូវទេ ទើបអាចនាំយើងឲ្យត្រឡប់រកព្រះដែលនៅឯស្ថានសួគ៌បាន! ចូរយើងកុំធ្វើដូចជាស្តេចហេរ៉ូឌ។ សូមយើងចងចាំថាព្រះយេស៊ូវយាងមកធ្វើជាព្រះអង្គសង្គ្រោះសម្រាប់យើងរាល់គ្នា។

## ៦. សំនួរពិភាក្សា

១. តើស្តេចរបស់ជនជាតិអ៊ីស្រាអែលមានឈ្មោះអ្វី? *(ស្តេចហេរ៉ូឌ)*

២.តើនរណាមិនសប្បាយចិត្តដែលព្រះយេស៊ូវដែលជាស្តេចនៃសាសន៍អ៊ីស្រាអែលបានចាប់កំណើត? *(ស្តេចហេរ៉ូឌ)*

៣. តើនរណាមកគាល់ស្តេចហេរ៉ូឌ ដើម្បីសួរពីកំណើតរបស់ព្រះយេស៊ូវ? *(ពួកហោរទាំង៣)*

៤. ហេតុអ្វីបានជា ស្តេចហេរ៉ូឌ សុំឲ្យហោរទាំងបី ប្រាប់ឲ្យគាត់ដឹងផងថាតើបុត្រដែលទើបនឹងប្រសូតនោះនៅឯណា? *(គឺដើម្បីសម្លាប់ស្តេចដែលទើបនឹងប្រសូត)*

៥. តើនរណាដែលមករកយើងដើម្បីជួយយើងឲ្យត្រឡប់ទៅរកព្រះនៅឯងស្ថានសួគ៌វិញ? *(ព្រះយេស៊ូវ)*

### ៧. ល្បែងកំសាន្ត និយាយ "ចាស ឬបាទ"

ក. សូមបែងចែកកុមារជាក្រុម ដែល១ក្រុមមានគ្នាពី៣ទៅ៤នាក់។ ជ្រើសរើសកុមារម្នាក់ឲ្យដើរតួជាអ្នកដែលមិនជឿលើព្រះយេស៊ូវ។ កុមារផ្សេងទៀតត្រូវស្វែងរកហេតុផលល្អៗ ដើម្បីបញ្ចុះបញ្ចូលឲ្យមិត្តរបស់គេម្នាក់នោះនឹងនិយាយថា " បាទ ឬចាស " ចំពោះព្រះយេស៊ូវ។

ខ.បន្ទាប់ពីទុកពេលឲ្យក្រុមនីមួយៗត្រៀមរួច ហើយសូមឱ្យពួកគេឡើងមកបង្ហាញពីរបៀបដែលពួកគេបានសម្រេចចិត្តនិយាយបញ្ចុះបញ្ចូលមិត្តរបស់ពួកគេឱ្យជឿលើព្រះយេស៊ូវ។

គ. សួរកុមារដែលបានជ្រើសរើសនៅក្នុងក្រុមនីមួយៗថា ប្រសិនបើពួកគេត្រូវបានគេបញ្ចុះបញ្ចូល។ បន្ទាប់ មកសួរសំនួរពួកគេថា "តើអ្នកជឿព្រះយេស៊ូវទេ?" កុមារដែលត្រូវបានជ្រើសរើសនោះនឹងឆ្លើយថា " បាទ ឬចាស ខ្ញុំជឿព្រះយេស៊ូវ" ។

### ៨. ខគម្ពីរចងចាំ

**យ៉ូហាន ៣៖១៦** *"ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះមិនត្រូវវិនាសឡើយគឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ "*។

### ៩. ហត្ថកម្ម

សំភារៈដែលត្រូវការ៖ សូមបោះពុម្ពគំរូប្រអប់ ខគម្ពីរ **យ៉ូហាន ៣៖១៦** សំរាប់កុមារ ម្នាក់ៗ



១. សូមឲ្យក្រដាសដែលបានថតចំលងទៅកុមារម្នាក់១សន្លឹក ហើយឲ្យកុមារតុបតែងឬផាត់ពណ៌លើក្រដាសដូចដែលពួកគេចងចាំនិយាយ ខគម្ពីរចងចាំរត់មាត់ហើយ។

២. ពេលដែលពួកគេបានតុបតែងចប់ហើយ ពួកគេអាចកាត់ក្រដាសនោះដោយប្រុង-ប្រយត្ន័ ហើយបត់ក្រដាសនោះអោយចេញជាប្រអប់។

៣. ឲ្យកុមារគិតពីរបៀបដែលរូបនីមួយៗមានន័យយ៉ាងដូចម្តេចផ្អែកទៅលើខគម្ពីរ។

### ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
យើងត្រូវការព្រះអង្គសង្គ្រោះ ពីព្រោះយើងមិនអាចជួយខ្លួនយើងឲ្យរួចអំពើបាបបានទេ។ អំពើបាបបំបែកយើងចេញពីព្រះ។ ព្រះយេស៊ូវយាងមករកយើង ដើម្បីលោះបាបយើងដោយទ្រង់បានសុគតលើឈើឆ្កាងសំរាប់យើង។ នេះជាក្តីស្រឡាញ់ដ៏អស្ចារ្យ ហើយជាការលះបង់ដ៏ធំផង។ជាអកុសលមិនមែនគ្រប់គ្នាជឿថា ព្រះយេស៊ូវគឺជាព្រះអង្គសង្គ្រោះ ដែលបានយាងមកជួយសង្គ្រោះយើងនោះទេ។ វាជាទំនួលខុសត្រូវរបស់យើងក្នុងការចែកចាយដំណឹងល្អនេះ ជាមួយមនុស្សក្នុងជីវិតរបស់យើង។

សប្តាហ៍នេះ សូមគិតអំពីនរណាម្នាក់ដែលមិនស្គាល់ព្រះយេស៊ូវ ហើយអធិស្ឋានសម្រាប់ពួកគេ។ រួចប្រាប់ពួកគេអំពីព្រះយេស៊ូវ។




ដ្បិតព្រះទ្រង់ស្រឡាញ់
មនុស្សលោក ដល់ម្ល៉េះ
បានជាទ្រង់ប្រទានព្រះ
រាជបុត្រាទ្រង់តែ១

ដើម្បីឲ្យអ្នកណាដែល
ជឿដល់ព្រះរាជបុត្រា
នោះ មិនត្រូវវិនាស
ឡើយ

គឺឲ្យមានជីវិតអស់
កល្បជានិច្ចវិញ
**យូហាន ៣:១៦**



